## របាយការណ៍របស់សហចៅក្រមរបាយការណ៍អនុលោមតាមវិធាន ១០៨(៥) នៃវិធានផ្ទៃក្នុង

### I. របាយការណ៍របស់សហចៅក្រមរបាយការណ៍សម្រាប់វគ្គសវនាការស្ដីពី“ឧទ្ធរណ៍បណ្ដឹងសាធុក្ខពាក់ព័ន្ធនៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី”

*សហចៅក្រមរបាយការណ៍៖* **ចៅក្រម CHANDRA NIHAL JAYASINGHE និងចៅក្រម ម៉ុង មុនីចរិយ៉ា**

១. សារណាចម្បងរបស់ជនជាប់ចោទបានលើកឡើងថា៖ “ការដែលអង្គជំនុំជម្រះខកខានក្នុងការចេញសំអាងហេតុពេញលេញសម្រាប់សាលក្រមនៅថ្ងៃដែលសាលក្រមត្រូវបានប្រកាស គឺជាការប្រព្រឹត្តកំហុសធ្ងន់ធ្ងរផ្នែកអង្គច្បាប់ដែលនាំឱ្យសាលក្រម ដែលខ្លួនបានប្រកាសនោះទៅជាមោឃៈ ដោយសារវិការៈផ្នែកនីតិវិធី។ ការចេញសំអាងហេតុនាពេលក្រោយ ពុំអាចជួសជុលការវិការៈនេះបានឡើយ”។ សារណានេះបានអះអាងបន្ថែមទៀតថា ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង*បានផុតអាណត្តិរបស់ខ្លួន* នៅពេលសាលក្រមមានសំអាងហេតុពេញលេញអង្គជំនុំជម្រះសាលាដំបូង ត្រូវបានចេញនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ និងថា ទង្វើរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញសាលក្រមមានសំអាងហេតុពេញលេញ គឺធ្វើតាមអំពើចិត្ត និង*ហួសពីដែនកំណត់នៃច្បាប់*។

២. **ជាជម្រើស ជនជាប់ចោទបានលើកឡើងថា ការជំនុំជម្រះទាំងមូលបានធ្វើឡើងដោយពុំមានភាពយុត្តិធម៌** និងថា សិទ្ធិមូលដ្ឋានរបស់គាត់ដូចមានចែងក្នុងក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ពុំត្រូវបានគោរពចាប់តាំងពីដើមរហូតដល់ចុងបញ្ចប់នៃការជំនុំជម្រះ មានដូចជា៖ វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈលម្អៀងចំពោះគោលការណ៍បំភ្លឺស្ដីពីច្បាប់ព្រហ្មទណ្ឌ និងកិច្ចដំណើរការនីតិវិធីដែលមាននៅក្នុងការជំនុំជម្រះដំបូងរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ និងភាពលម្អៀងចំពោះភស្តុតាង ដែលទាំងអស់នេះបានធ្វើឱ្យការជំនុំជម្រះលើជនជាប់ចោទមានភាពមិនយុត្តិធម៌។ ដូច្នេះ ជនជាប់ចោទបានស្នើសុំឱ្យបដិសេធការសម្រេចដាក់ពិរុទ្ធភាព និងការប្រកាសទោសមកលើរូបគាត់។ ជនជាប់ចោទបានលើកនូវចំណុចជាក់លាក់បន្ថែមទៀតពាក់ព័ន្ធទៅនឹងវិធីសាស្ត្រដែលមានលក្ខណៈលម្អៀង និងថា ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើ**គោលការណ៍នីត្យានុកូលភាព**ដោយខកខានក្នុងការអនុវត្តតាមបទដ្ឋានគតិយុត្តិត្រឹមត្រូវក្នុងការពិនិត្យលើបញ្ហាថា តើបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់នោះ ឬទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានរកឃើញនោះ គ្រប់គ្រាន់អាចយល់ដឹងបានថាជាបទល្មើស និងមានច្បាប់ចែងក្នុងឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា និងរួមបញ្ចូលនូវបញ្ហាដែលថា តើលក្ខខណ្ឌធាតុផ្សំ*តាមបរិបទ*នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវបានបំពេញដែរ ឬយ៉ាងណា។ ជាពិសេស គាត់បានលើកឡើងថា អង្គជំនុំ

ជម្រះសាលាដំបូងបានដាក់ទម្ងន់ពុំសមស្របចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ក្រៅតែពីការអនុវត្តច្បាប់ជាធរមាននាពេលនោះ និងបានសន្និដ្ឋានថា ទាំងនេះគឺជាកំហុសអង្គច្បាប់ ដែលរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការស្តាប់ដោយតុលាការព្រហ្មទណ្ឌឥតលម្អៀង។ គាត់បានលើកឡើងថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះពុំមានលក្ខណៈត្រឹមត្រូវ ដែលអាចស្មើនឹងកំហុសអង្គច្បាប់ ដែលនាំឱ្យអង្គជំនុំជម្រះធ្វើការយល់ឃើញពុំត្រឹមត្រូវ ដែលជាមូលដ្ឋានក្នុងការសម្រេចដាក់ពិរុទ្ធភាពមកលើរូបគាត់។

៣. បន្ថែមលើនេះ ជនជាប់ចោទបានជំទាស់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលមានលក្ខណៈមិនច្បាស់លាស់ និងទូលំទូលាយទៅលើ**វិសាលភាពនៃសំណុំរឿង ០០២/០២** នាំឱ្យមានការពិចារណាលើអង្គហេតុនៅក្រៅវិសាលភាពសំណុំរឿង និងលើអង្គហេតុដែលពុំជាប់ពាក់ព័ន្ធទៅនឹងបទចោទទាំងនោះ។ គាត់បានអះអាងថា កំហុសទាំងនេះបានរំលោភបំពានលើសិទ្ធិទទួលបានការជូនដំណឹងអំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងនឹងរូបគាត់ និងទទួលបានពេលវេលាគ្រប់គ្រាន់ ព្រមទាំងគ្រឿងបរិក្ខារសម្រួលសម្រាប់ការត្រៀមរៀបចំការការពារខ្លួនដូចមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ គាត់បានអះអាងថា កំហុសអង្គច្បាប់ទាំងនេះបង្ហាញពីកង្វះអនាគតិរបស់អង្គជំនុំជម្រះសាលាដំបូង។

៤. ទាក់ទងទៅនឹងអំណះអំណាងស្តីពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយតុលាការព្រហ្មទណ្ឌត្រឹមត្រូវឥតលម្អៀង ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយពុំបានដោះស្រាយការចោទប្រកាន់របស់គាត់អំពីការកង្វះនូវអនាគតិ ដែលបានកើតឡើងដោយសារអង្គជំនុំជម្រះដដែលធ្វើការជំនុំជម្រះសំណុំរឿង ០០២/០១ ដែលរូបគាត់ គឺជាជនជាប់ចោទ។ ការណ៍នេះបានធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងបង្កើតការសម្រេចដាក់ពិរុទ្ធភាពថ្មីក្នុងសំណុំរឿង ០០២/០២ ចេញពីអង្គហេតុដែលសាលដីកាស្ថាពរបានចេញរួចហើយក្នុងសំណុំរឿង ០០២/០១។ <u>**បើទោះបីជាបញ្ហានេះត្រូវបានជំនុំជម្រះ និងសម្រេចពីមុនរួចមកហើយ ជនជាប់ចោទអាចផ្តោតសារណារបស់ខ្លួនលើបញ្ហានេះបន្ថែមទៀតនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។**</u>

៥. ជនជាប់ចោទបានអះអាងថា ភាពលម្អៀងរបស់អង្គជំនុំជម្រះត្រូវបានបង្ហាញបន្ថែមទៀតតាមរយៈការកែប្រែប្រភេទបទចោទនៃការសម្លាប់រង្គាលទៅជាអំពើមនុស្សឃាត ដែលមានធាតុផ្សំអត្តនោម័តិមិនច្បាស់លាស់នៃ*ចេតនាប្រយោល*។ គាត់បានលើកឡើងថា បញ្ហានេះគាត់ពុំត្រូវបានជូនដំណឹង ដូច្នេះជាការរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជូនដំណឹងអំពីប្រភេទនៃបទចោទប្រឆាំងនឹងរូបគាត់ និងមានពេលវេលា និងគ្រឿងបរិក្ខារសម្រួលគ្រប់គ្រាន់សម្រាប់ត្រៀមរៀបចំការការពារខ្លួនគាត់។ <u>**ជនជាប់ចោទអាចលើកនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលពីមូលហេតុ ដែលបញ្ហានេះតម្រូវឱ្យធ្វើការតវ៉ាសាឡើងវិញ**</u>។

៦. បន្ថែមលើនេះទៀត ជនជាប់ចោទបានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តពុំស្របគ្នានូវគោលការណ៍ ដែលពុំគប្បីមានការប្រើប្រាស់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែមួយលើរឿងក្តីពីរនោះទេ។ **គាត់អាចលើកបង្ហាញបន្ថែមផ្អែកលើការប្រើប្រាស់វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងការបំភ្លឺពីអង្គជំនុំជម្រះតុលាការកំពូលថា បើទោះបីជាសំណុំរឿង ០០២/០១ ត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទដែលនៅសេសសល់ និងការចោទប្រកាន់ផ្អែកអង្គហេតុប្រឆាំងនឹងជនជាប់ចោទនៅដំណាក់ជំនុំជម្រះក្រោយនេះយ៉ាងណាក៏ដោយ ក៏តាមការបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបង្ហាញច្បាស់លាស់ថា ពុំគប្បីមានការប្រើប្រាស់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែមួយក្នុងរឿងក្តីពីរនោះទេ និងថា ការយល់ឃើញផ្អែកអង្គហេតុ ពុំអាចត្រូវផ្ទេរពីសំណុំរឿង ០០២/០១ មកសំណុំរឿង ០០២/០២ បានឡើយ។ អាស្រ័យហេតុនេះ បើទោះបីជាភស្តុតាងនៅតែមានលក្ខណៈរួមជាទូទៅចំពោះរឿងក្តីដែលត្រូវបានបំបែកក៏ដោយ ក៏លក្ខណៈរួមនេះពុំអាចពន្លាតវិសាលភាពដល់ការយល់ឃើញ ហើយធាតុផ្សំផ្អែកអង្គហេតុរួមនៅគ្រប់ករណីទាំងអស់ដែលកើតចេញពីសំណុំរឿង ០០២ ត្រូវតែធ្វើការបង្ហាញសាជាថ្មីម្តងទៀត**។

៧. ជនជាប់ចោទបានលើកឡើងថា ការបដិសេធរបស់អង្គជំនុំជម្រះក្នុងការទទួលយកសំណើរបស់គាត់សុំឱ្យកោះហៅសាក្សីសាឡើងវិញពីសំណុំរឿង ០០២/០១ ពុំមានលក្ខណៈស៊ីសង្វាក់គ្នាជាមួយនឹងការសម្រេចពីមុនរបស់អង្គជំនុំជម្រះ**ដែលបានអនុញ្ញាតការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយរាប់រយពីសំណុំរឿង ០០៣ និង ០០៤** ក្រោយមកទៀតក្នុងពេលជំនុំជម្រះ។ កំណត់ហេតុស្តាប់ចម្លើយទាំងនេះ ពុំបានបែងចែកច្បាស់លាស់រវាងភស្តុតាងដោះបន្ទុក និងដាក់បន្ទុក និងបានអូសបន្លាយពេលវេលានៃការជំនុំជម្រះ ដោយរំលោភបំពានលើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដេញដោលចំពោះមុខ និងទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលឥតសមហេតុផលឡើយ។ **ជនជាប់ចោទអាចពិចារណាដោយផ្តោតលើអ្វីខ្លះដែលជាភស្តុតាងដោះបន្ទុកត្រូវបានមើលរំលងនោះ**។

៨. ប្រធានបទនៃភាពលម្អៀង និងភាពមិនយុត្តិធម៌ដែលបានចោទប្រកាន់ បានបង្ហាញឱ្យឃើញបន្ថែមនៅក្នុងសេចក្តីសម្រេចបន្ទាន់ភ្លាមៗពាក់ព័ន្ធទៅនឹងបញ្ហាភស្តុតាងដែលបានលើកឡើងក្នុងអំឡុងពេលនៃការជំនុំជម្រះ។ សេចក្តីសម្រេចនេះអាចស្មើនឹងកំហុសដែលស្តែងឱ្យដឹងតាមរយៈការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបង្កឱ្យមានព្យសនកម្មដល់រូបគាត់។ សេចក្តីសម្រេចនេះពាក់ព័ន្ធទៅនឹង៖

*(i) លំដាប់លំដោយនៃការស្តាប់សាក្សី*

*(ii) ការទទួលយកភស្តុតាងក្នុងអំឡុងពេលនៃសវនាការដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង*

*(iii) ការទទួលយកភស្តុតាងរបស់អ្នកស្រាវជ្រាវ និងអ្នកប្រវត្តិសាស្ត្រដែលពុំបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង*

*(iv) ការបង្ហាញភស្តុតាងពីសំណុំរឿង ០០៣ និង ០០៤*

*(v) ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបើកកិច្ចដំណើរការនីតិវិធីជំនុំជម្រះសាឡើងវិញ និងការទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីជាក់លាក់ពីររូប ដែលត្រូវបានបង្ហាញជាសាធារណៈក្នុងអំឡុងពេលនៃដំណាក់កាលការពិភាក្សាសម្រេចនៃការជំនុំជម្រះ*

*(vi) វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាង ជាទូទៅ*

៩. អំណះអំណាងនៃភាពមិនយុត្តិធម៌បានលើកឡើងពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តន៍បទដ្ឋានទទួលយកភស្តុតាងដែលហួសពីវិមតិសង្ស័យ និងការអនុវត្តន៍ដែលអនុញ្ញាតឱ្យសាក្សីពិនិត្យមើលឡើងវិញនូវចម្លើយរបស់ខ្លួនមុនពេលផ្តល់សក្ខីកម្មក្នុងតុលាការ។ ការផ្តល់អាទិភាពលើភាពឆាប់រហ័សជាងការស្វែងការពិត វិធីសាស្ត្រប្រើប្រាស់ចំពោះភស្តុតាងជាក់លាក់មួយភេទ ជាពិសេសការប្រើប្រាស់ចម្លើយ និងអត្ថបទផ្សព្វផ្សាយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ការសំអាងទៅលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ការសំអាងលើភស្តុតាងចចាមអារ៉ាម និងលើឯកសារដែលមានប្រភពចម្រូងចម្រាស។ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តវិធីសាស្ត្រផ្សេងៗគ្នា នៅពេលដោះស្រាយលើភស្តុតាងដាក់បន្ទុក ដែលផ្ទុយពីភស្តុតាងដោះបន្ទុក និងវិធីសាស្ត្រលើតម្លៃជាភស្តុតាងនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អានុភាពនៃការរំលោភបំពានទាំងអស់បូកបញ្ចូលគ្នា បានបណ្តាលឱ្យការជំនុំជម្រះរបស់គាត់មានភាពមិនយុត្តិធម៌ដល់កម្រិតមួយ ដែលអង្គជំនុំជម្រះតុលាការកំពូលគប្បីធ្វើអន្តរាគមន៍បដិសេធការសម្រេចដាក់ពិរុទ្ធភាព និងការប្រកាសទោសនេះ។ **<u>អង្គជំនុំជម្រះស្វាគមន៍ចំពោះការយោងជាក់លាក់ពាក់ព័ន្ធទៅនឹងការពិនិត្យភស្តុតាងមិនស៊ីសង្វាក់គ្នាដែលបានចោទប្រកាន់ ជាពិសេសភស្តុតាងដោះបន្ទុកដែលជនជាប់ចោទបានយល់ឃើញថា ពុំត្រូវបានអើពើ ឬពិនិត្យដោយពុំស្របគ្នានោះ</u>**។

១០. ជាងចុងក្រោយ ខ្ញុំសូមបញ្ចប់នូវរបាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខរបស់ជនជាប់ចោទពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ។

## II. **របាយការណ៍របស់សហចៅក្រមរបាយការណ៍សម្រាប់វគ្គស្តីពី "ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង"**

*សហចៅក្រមរបាយការណ៍:* **ចៅក្រម សោម សិរីវឌ្ឍ និង ចៅក្រម** Maureen Harding CLARK

១១. ជនជាប់ចោទបានលើកទឡ្ហីករណ៍មួយចំនួននៃបណ្តឹងសាទុក្ខជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការជំនុំជម្រះអង្គហេតុមួយចំនួន និងជំទាស់ទៅនឹងការយល់ឃើញដែលពាក់ព័ន្ធ។ សារណាការរបស់គាត់ត្រូវបានសង្ខេបជាបួនចំណុចសំខាន់ៗដូចខាងក្រោម៖

១២. ទីមួយ ជនជាប់ចោទបានលើកឡើងថា អង្គហេតុមួយចំនួនដែលបានផ្អែកទៅលើក្នុងការបង្ហាញពីបទឧក្រិដ្ឋ **គឺពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ/ការបញ្ជូលសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេត** ដោយសារអង្គហេតុទាំងនេះពុំត្រូវបានបញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាឡើយ។ ជនជាប់ចោទបានអះអាងថា រួមទាំងអង្គហេតុដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅសហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម និងការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ភ្នំក្រោល ក្រាំងតាចាន់ និងអូរកន្សែង។ សារណាក៏បានរួមបញ្ចូលផងដែរនូវការបោសសម្អាតផ្ទៃក្នុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ លើកលែងតែអង្គហេតុដែលបានកើតឡើងក្នុងភូមិភាគឧត្តរនៅក្នុងឆ្នាំ ១៩៧៦ និងភូមិភាគបូព៌ាក្នុងឆ្នាំ ១៩៧៨។ ការប្រព្រឹត្តទៅលើអ្នកកាន់ពុទ្ធសាសនានៅសហករណ៍ត្រាំកក់ និងអង្គហេតុពាក់ព័ន្ធទៅនឹងគោលនយោបាយទូទាំងប្រទេសចំពោះអ្នកកាន់ពុទ្ធសាសនា និងការប្រព្រឹត្តទៅលើជនជាតិចាមដែលចេញឆ្ងាយពីអង្គហេតុដែលបានកើតឡើងបន្ទាប់ពីឆ្នាំ ១៩៧៧ ក្នុងស្រុកកងមាស និងក្រូចឆ្មា។ អំណះអំណាងដដែលបានលើកឡើងនូវការប្រព្រឹត្តទៅលើជនជាតិវៀតណាមដែលពុំស្ថិតក្នុងខេត្តស្វាយរៀង ព្រៃវែង និងការឈ្លានពានចូលប្រទេសវៀតណាម។

១៣. ជនជាប់ចោទបានជំទាស់ទៅនឹងការពិចារណាលើអង្គហេតុទាំងអស់សម្រាប់បទឧក្រិដ្ឋ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នីមួយៗនៃបទឧក្រិដ្ឋ និងទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដែលត្រូវបានចោទប្រកាន់ថា ពុំស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ មានដូចជា៖

> បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការនិរទេស ការដាក់ឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតដូចជា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ

និងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។

១៤. នៅចំណុចបន្ទាប់នៃទឡ្ហីករណ៍បណ្តឹងសាទុក្ខ ជនជាប់ចោទបានជំទាស់ទៅនឹងការបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា ការជំទាស់របស់គាត់ទៅនឹងការបញ្ជូនសំណុំរឿង/យុត្តាធិការលើបទចោទដែលបានលើកឡើងនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់គាត់ បានធ្វើឡើងយឺតពេល។ ជនជាប់ចោទបានជំទាស់ទៅនឹងការបកស្រាយវិធាន ៨៩ នៃវិធានផ្ទៃក្នុង និងលើកឡើងថា ការបកស្រាយពុំត្រឹមត្រូវលើវិធាន ៨៩ នៃវិធានផ្ទៃក្នុង មានន័យថា ការយល់ឃើញណាមួយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធទៅនឹងទីកន្លែង និងព្រឹត្តិការណ៍ប្រព្រឹត្តបទឧក្រិដ្ឋខាងលើ ត្រង់ចំណុចពាក់ព័ន្ធទៅនឹងអង្គហេតុដែលពុំស្ថិតក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ត្រូវបដិសេធចោល។ **អង្គជំនុំជម្រះស្នើជនជាប់ចោទពន្យល់ពីមូលហេតុដែលខ្លួនពុំបានលើកការជំទាស់ទាំងនេះ តាំងពីដំបូងនៅមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ បន្ទាប់មកទៀត នៅពេលសវនាការចាប់ផ្តើមលើអញ្ញត្រកម្មបឋម និងផ្តល់សេចក្តីយោងជាក់លាក់ត្រង់ចំណុចដែលជនជាប់ចោទបានលើកនៅដំណាក់កាលមុនការជំនុំជម្រះ និងថាបញ្ហានេះពុំត្រូវបានសម្រេចពិតប្រាកដដូចដែលបានអះអាងនៅក្នុងសារណាបណ្តឹងសាទុក្ខ**។

១៥. ទីពីរ ជនជាប់ចោទបានលើកឡើងថា បទចោទមួយចំនួននៅក្នុងដីកាដំណោះស្រាយ ខ្វះភាពច្បាស់លាស់ និងគ្រប់គ្រាន់ដើម្បីបំពេញតាមបទដ្ឋានអប្បបរមាស្តីពីការបង្ហាញភស្តុតាងចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋទាំងនោះ និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ នៅពេលដែលអង្គជំនុំជម្រះបានបដិសេធសារណារបស់ខ្លួនដែលជំទាស់ទៅនឹងកង្វះភស្តុតាងដែលអាចជឿជាក់ រឹងមាំ និងស៊ីសង្វាក់គ្នាដែលជាមូលដ្ឋាននៃបទចោទ។ **អង្គជំនុំជម្រះស្វាគមន៍ការបំភ្លឺអំពីការយល់ឃើញនៅដំណាក់កាលមុនការជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតដែលពាក់ព័ន្ធទៅនឹងបទចោទនៅក្នុងដីកាដំណោះស្រាយ និងបន្ទាប់មកការយល់ឃើញអំពីពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូងនៃបទចោទមួយចំនួននៅក្នុងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះតុលាការកំពូលតម្រូវឱ្យមានការបំភ្លឺលើចំណុចនេះដូចដែលបានលើកឡើងក្នុងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ**។

១៦. ទីបី អង្គជំនុំជម្រះសាលាដំបូងបានបកស្រាយដីកាដំណោះស្រាយពុំត្រឹមត្រូវដោយពិចារណាលើបទឧក្រិដ្ឋដែលពុំស្ថិតក្នុង**វិសាលភាពយុត្តាធិការដែលជាកម្មវត្ថុនៃរឿងក្តីរបស់ខ្លួន**។ កំហុសអង្គច្បាប់នេះនាំឱ្យអង្គជំនុំជម្រះសាលាដំបូងជំនុំជម្រះអង្គហេតុនៅក្រៅវិសាលភាពរបស់ខ្លួន និងឈានដល់ការយល់ឃើញដែលគប្បី

ត្រូវបដិសេធចោលនាពេលនេះ។ ការយល់ឃើញនេះបានរួមបញ្ចូលអង្គហេតុពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មី ទាហាននៃរបបសាធារណរដ្ឋខ្មែរ និងសត្រូវពិតប្រាកដ និងតាមការសន្មតនៅការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខផ្សេងៗ។ ការយល់ឃើញផ្នែកអង្គហេតុទាំងអស់ទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា អំពើមនុស្សឃាត ការសម្លាប់រង្គាលកំណត់គោលដៅលើជនជាតិវៀតណាមនៅក្នុងទឹកដីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងអំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើជនជាតិចាម ត្រូវបានជំទាស់ក្រោមយុត្តាធិការដែលជាកម្មវត្ថុនៃរឿងក្តី។

១៧. ទីបួន អង្គហេតុដែលត្រូវបាន**ដកចេញតាមរយៈដីកាបំបែកកិច្ចដំណើរការនីតិវិធី** ត្រូវបានដាក់បញ្ចូលមកវិញដោយអង្គជំនុំជម្រះសាលាដំបូង ដែលបន្ទាប់មកបានជំនុំជម្រះលើអង្គហេតុដែលស្ថិតនៅក្រៅយុត្តាធិការរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងពុំមានសមត្ថកិច្ចស្តាប់អង្គហេតុដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចជា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អំពើអមនុស្សធម៌ដទៃទៀតពាក់ព័ន្ធទៅនឹងការផ្លាស់ទីជនជាតិចាមដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៃជនជាតិវៀតណាម។ ដូចគ្នានេះដែរ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូង**ពុំតម្រូវឱ្យជំនុំជម្រះ**អង្គហេតុពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចជា អំពើអមនុស្សធម៌ដទៃទៀតតាមរយៈការផ្លាស់ទីជនជាតិចាមដោយបង្ខំក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ ដោយសារជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពរួចហើយពីបទឧក្រិដ្ឋតែមួយដូចគ្នាក្នុងសំណុំរឿង ០០២/០១។ **អង្គជំនុំជម្រះតុលាការកំពូលស្នើផ្តល់សេចក្តីយោងជាក់លាក់ទៅលើផ្នែកនៃសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលចោទថា បកស្រាយពុំត្រឹមត្រូវនោះ**។

១៨. ជាងចុងក្រោយ ខ្ញុំសូមបញ្ចប់នូវរបាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង។

## III. របាយការណ៍របស់សហចៅក្រមរបាយការណ៍សម្រាប់វគ្គស្តីពី“ឧឡារិកភាពនៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធ”

*សហចៅក្រមរបាយការណ៍៖* **ចៅក្រម FLORENCE NDEPELE MWACHANDE MUMBA និងចៅក្រម យ៉ា ណារិន**

១៩. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធពីបទឧក្រិដ្ឋមួយចំនួនក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមតាមរយៈការចូលរួមរបស់គាត់ក្នុងគោលបំណងរួម និងរួមចំណែកក្នុងចេតនាឧក្រិដ្ឋដូចគ្នាក្នុង‘សហឧក្រិដ្ឋកម្មរួម’។ គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋខាងក្រោមដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ៖

(ក) បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យក្លាយជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា ពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើដែលត្រូវបានចាត់ទុកថា ជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបការដោយបង្ខំ

(ខ) បទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់សមាជិកនៃជនជាតិភាគតិចវៀតណាមជាក្រុមជាតិសាសន៍

(គ) ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដោយការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបយ៉ាងអមនុស្សធម៌ ការបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិលតាមអនុសញ្ញាទីក្រុងហ្សឺណែវ នៅមន្ទីរសន្តិសុខ ស-២១។

២០. អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា ជនជាប់ចោទបានជួយទំនុកបម្រុងដល់បទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដូចជា ការធ្វើមនុស្សឃាត*ដោយចេតនាប្រយោល*នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ ១ មករា ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងភ្នំក្រោលពាក់ព័ន្ធទៅនឹងការស្លាប់កម្មករ និងកសិករនៅ

សហករណ៍ ការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខទាំងនោះ។

២១. ជនជាប់ចោទបច្ចុប្បន្នជំទាស់រាល់ការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋខាងលើ និងបានលើកកំហុសអង្គហេតុ និងអង្គច្បាប់។ អំណះអំណាងរបស់គាត់ត្រូវបានសង្ខេបដូចខាងក្រោម៖

២២. **កំហុសអង្គច្បាប់**៖ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើ**គោលការណ៍នីត្យានុកូលភាព**ដោយខកខានក្នុងការអនុវត្តតាមលក្ខណៈវិនិច្ឆ័យគតិយុត្តិ ក្នុងការពិនិត្យលើបញ្ហា ថាតើបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវនោះ ជនជាប់ចោទបានដឹងគ្រប់គ្រាន់ថាជាបទល្មើស និងមានច្បាប់ចែងក្នុងឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា។ ការសំអាងរបស់អង្គជំនុំជម្រះទៅលើកត្តាទាំងបីក្នុងការវិភាគរបស់ខ្លួន ត្រូវបានជំទាស់៖ កត្តាទាំងនោះមានអត្ថិភាពជាបទឧក្រិដ្ឋ ឬជាទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលប្រព្រឹត្តបទល្មើស ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងចុងក្រោយតួនាទីរបស់ជនជាប់ចោទជាសមាជិកនៃរដ្ឋអំណាចគ្រប់គ្រងរបស់កម្ពុជា។ គាត់អះអាងថា ការអនុវត្តនូវលក្ខណៈវិនិច្ឆ័យទាំងនេះ មានកំហុសអង្គច្បាប់ដែលធ្វើឱ្យការយល់ឃើញ និងការដាក់ពិរុទ្ធភាពទាំងអស់ទៅជាមោឃៈ។ **<u>អំណះអំណាងដែលពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ស្តីពីគោលការណ៍នីត្យានុកូលភាព ត្រូវបានលើកឡើងជាច្រើនដងក្នុងសារណារបស់ជនជាប់ចោទ។ អង្គជំនុំជម្រះជឿជាក់ថា ការជំទាស់ទៅនឹងនីត្យានុកូលភាពនៃបទឧក្រិដ្ឋជាក់លាក់ ជាការសមស្របអាចត្រូវធ្វើឡើងនៅក្នុងផ្នែក ស្តីពីបទឧក្រិដ្ឋនេះ</u>**។

២៣. ជនជាប់ចោទបានជំទាស់ទៅនឹងការផ្តល់និយមន័យផ្នែកច្បាប់នៃអំពើមនុស្សឃាត *ដោយចេតនាប្រយោល* និងលើកឡើងថា ពុំមានអត្ថិភាពនៃទស្សនៈស្តីពីអំពើមនុស្សឃាត*ដោយចេតនាប្រយោល*ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ឡើយ។ អាស្រ័យហេតុនេះ រាល់ការយល់ឃើញនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនេះ ត្រូវបដិសេធចោល។ **<u>អត្ថិភាពនៃអំពើមនុស្សឃាត*ដោយចេតនាប្រយោល*ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ ត្រូវបានសម្រេចតាំងពីដំបូងរួចមកហើយក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះស្វាគមន៍ការបំភ្លឺលើមូលហេតុដែលត្រូវលើកបញ្ហានេះមកតវ៉ាសាជាថ្មី</u>**។

២៤. ជាជម្រើសដល់ការជំទាស់ច្រើនចំណុចទៅនឹងការយល់ឃើញនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើការស្លាប់របស់ប្រជាជនដោយសារលក្ខខណ្ឌនៃការធ្វើការ ការរស់នៅ និងការឃុំឃាំងនៅការដ្ឋានធ្វើការ សហករណ៍ និងមន្ទីរសន្តិសុខផ្សេងៗ ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង**ខកខានក្នុងការផ្តល់និយមន័យផ្នែកច្បាប់ស្តីពីកំហុសអសកម្ម**ដែលឈានទៅដល់ការយល់ឃើញពុំត្រឹមត្រូវពាក់ព័ន្ធទៅនឹងការស្លាប់នៅកន្លែងប្រព្រឹត្តបទល្មើសនានា។

២៥. បន្ថែមលើនេះ ជនជាប់ចោទបានអះអាងថា **ពុំមានភស្តុតាងគ្រប់គ្រាន់**សម្រាប់ការដាក់ពិរុទ្ធភាពឱ្យហួសពីវិមតិសង្ស័យសម្រាប់អំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម។

២៦. អំណះអំណាងពាក់ព័ន្ធមួយចំនួនបានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាង ក្នុងការបង្ហាញធាតុផ្សំអត្តនោម័ត និង/ឬ សត្យានុម័ត សម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាលដោយរួមបញ្ចូលការសម្លាប់ក្នុងទ្រង់ទ្រាយធំលើជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ ក្រចេះ និងនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ និងជនជាតិចាម នៅវត្តអូរត្រកួនក្នុងឆ្នាំ ១៩៧៧ និងភូមិទ្រា។

២៧. ជនជាប់ចោទបានជំទាស់ទៅនឹងការផ្តល់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីធាតុផ្សំចាំបាច់នូវបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ដែលតាមការលើកឡើង បាននាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើអ្នកកាន់ពុទ្ធសាសនា និងជនជាតិចាម។ ជាពិសេស ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្តល់និយមន័យនៃធាតុផ្សំអត្តនោម័តសម្រាប់បទឧក្រិដ្ឋទាំងនោះ។

២៨. ជនជាប់ចោទបានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការដាក់ពិរុទ្ធពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ**ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ**លើប្រជាជនថ្មី អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ សត្រូវពិតប្រាកដ ឬតាមការសន្មត ឬជនជាតិចាមដែលត្រូវបានកំណត់គោលដៅដាក់លាក់ និងដាក់ឱ្យស្ថិតក្រោមការប្រព្រឹត្តទៅលើដោយរើសអើង។

២៩. ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញនូវបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ**ការធ្វើទុក្ខបុកម្នេញ**ដោយសារមូលហេតុពូជសាសន៍លើជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ដូចការលើកឡើងដោយជនជាប់ចោទថា ជនជាតិវៀតណាមនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ពុំមែនជាក្រុមពូជសាសន៍ជាក់លាក់នោះឡើយ។ អំណះអំណាងដដែលបានលើកឡើងពាក់ព័ន្ធទៅនឹងការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមតាមរយៈការនិរទេស ការចាប់ខ្លួន និងការធ្វើមនុស្សឃាតដោយមូលហេតុពូជសាសន៍ និងចេតនារើសអើងក្នុងកម្រិតនៃលក្ខខណ្ឌតម្រូវ។

៣០. អំណះអំណាងមួយចំនួនពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ បានលើកឡើងទាក់ទងទៅនឹងការផ្លាស់ទីដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការរំលោភសេពសន្ថវៈ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ"**អំពើអមនុស្សធម៌**

**ដទៃទៀត**"។ ការជំទាស់ជាបឋម គឺពាក់ព័ន្ធទៅនឹង (ក) ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីច្បាប់ដែលអាចអនុវត្តបានលើ"អំពើអមនុស្សធម៌ដទៃទៀត" (ខ) ការខកខានក្នុងការពិចារណាលើបញ្ហាថា តើអង្គហេតុដែលជាបទឧក្រិដ្ឋត្រូវជនជាប់ចោទបានដឹងគ្រប់គ្រាន់ថាមានច្បាប់ចែងក្នុងឆ្នាំ ១៩៧៥ ដែរ ឬយ៉ាងណា។

៣១. ពាក់ព័ន្ធទៅនឹងការសម្រេចឱ្យជាប់ពិរុទ្ធពីបទនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ជាទូទៅ ជនជាប់ចោទជំទាស់ទៅនឹងកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុជាពិសេសលើបញ្ហាថាតើ ជនជាតិវៀតណាម គឺជាជនរងគ្រោះនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខភ្នំក្រោល ដែរ ឬយ៉ាងណា។

៣២. ជនជាប់ចោទបានជំទាស់លើបញ្ហា ថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្មែរក្រោមអាចជាជនរងគ្រោះនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំដែលជាអង្គហេតុត្រូវបានយកមកសំអាងនោះ ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរ ឬយ៉ាងណា និងបានជំទាស់បន្ថែមទៀតថា ភស្តុតាងនៃការប្រព្រឹត្តលើខ្មែរក្រោម ត្រូវបានប្រើប្រាស់ដោយពុំស្របច្បាប់ក្នុងការដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំលើជនជាតិវៀតណាម។

៣៣. អំពើអមនុស្សធម៌ដទៃទៀត ដែលមានចរិតលក្ខណៈជា**ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ**ក្នុងបរិបទនៃការរៀបការដោយបង្ខំ ត្រូវបានជំទាស់ដោយផ្អែកលើមូលដ្ឋានថា បទឧក្រិដ្ឋទាំងនោះពុំត្រូវបានជនជាប់ចោទអាចដឹងច្បាស់លាស់ថា មានច្បាប់ចែងជាក់លាក់ ដោយសារអំពើនោះពុំមែនជាការដាក់ទោសផ្នែកព្រហ្មទណ្ឌក្នុងច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិនៅពេលនោះ។ គាត់ជំទាស់ទៅនឹងអង្គហេតុដែលថា នត្ថិភាពនៃការព្រមព្រៀងគ្នារៀបអាពាហ៍ពិពាហ៍។ ការព្រមព្រៀងគ្នាគឺជាគោលការណ៍ដែលបានអនុម័តដោយបក្សកុម្មុយនីស្តកម្ពុជា ហើយការរៀបអាពាហ៍ពិពាហ៍ដែលបានរៀបចំឡើងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចគ្នាទៅនឹងការរៀបការដែលរៀបចំឡើងតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ ហេតុដូច្នេះ គាត់ជំទាស់ទៅនឹងនីត្យានុកូលភាពនៃការដាក់ពិរុទ្ធភាពក្រោមប្រធានបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

៣៤. បន្ទាប់ពីការដាក់ពិរុទ្ធភាពនៃអំពើអមនុស្សធម៌ដទៃទៀតដែលបានកើតចេញពីការរៀបការដោយបង្ខំ ជនជាប់ចោទបានលើកឡើងថា បើទោះបីជា អង្គហេតុដែលបានជំទាស់នោះត្រូវបានបង្ហាញក៏ដោយ ក៏ពុំអាចស្មើទៅនឹងកម្រិតលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលមានលក្ខណៈគ្រប់គ្រាន់ជាអំពើអមនុស្សធម៌ដទៃទៀតដែរ។ ដោយពុំមានការប៉ះពាល់ដល់សារណាដែលជាគន្លឹះសំខាន់ ជនជាប់ចោទបានជំទាស់ទៅនឹងអត្ថិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបង្ខំប្រជាជនឱ្យរៀបការ និងការរួមដំណេកអាពាហ៍ពិពាហ៍ដើម្បីបង្កើតកូនចៅសម្រាប់*អង្គការ*។

៣៥. ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃ**ការដាក់ឱ្យទៅជាទាសករ**ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ជនជាប់ចោទបានជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការជំនុំជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងទីកន្លែងប្រព្រឹត្តបទល្មើសមួយចំនួនមានដូចជា មន្ទីរសន្តិសុខភ្នំក្រោល។ បន្ថែមលើនេះ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយបានសំអាងលើភស្តុតាងមិនគ្រប់គ្រាន់ និងពុំអាចជឿទុកចិត្តបានក្នុងការយល់ឃើញថា មានអត្ថិភាពនៃបទឧក្រិដ្ឋនេះ។ ប្រហាក់ប្រហែលគ្នានេះដែរ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ គាត់បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលបង្កើតការយល់ឃើញអំពីការធ្វើទារុណកម្មលើជនជាតិចាម នៅមន្ទីរសន្តិសុខភូមិទ្រា។ **<u>អង្គជំនុំជម្រះស្វាគមន៍ចំពោះអំណះអំណាងដែលផ្តោតលើការជំទាស់ទាំងនេះ</u>**។

៣៦. ពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាមក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅត្រាំកក់ ជនជាប់ចោទបានលើកអំណះអំណាងដដែលដូចនៅពេលជំនុំជម្រះថា ឧបសម្ព័ន្ធនៃដីកាបំបែកកិច្ចដំណើរការនីតិវិធីជាភាសាបារាំងពុំមានបទចោទនេះទេ។ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយកំហុសនៃការខ្វះចន្លោះនេះរួចរាល់ហើយ ដែលបានកើតឡើងដោយសារបញ្ហានៃការបកប្រែជាភាសាបារាំង ប៉ុន្តែចំពោះសំណៅជាភាសាខ្មែរ និងអង់គ្លេសបានបង្ហាញបទចោទនេះ។ **អង្គជំនុំជម្រះតុលាការកំពូលស្នើសុំការពន្យល់ពីមូលហេតុដែលបញ្ហាដដែលនេះត្រូវបានលើកឡើងម្តងទៀតនៅក្នុងបណ្តឹងសាទុក្ខ**។ ជនជាប់ចោទបានជំទាស់បន្ថែមទៀតទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនៃ**ការនិរទេសជនជាតិវៀតណាម**ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងទីពីរ ថា បទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តឡើងដោយចេតនាដែលជាលក្ខខណ្ឌតម្រូវ ក្នុងការផ្លាស់ទីជនរងគ្រោះដោយបង្ខំឱ្យចេញផុតពីព្រំប្រទល់ជាតិ។

៣៧. គាត់បានជំទាស់រាល់ការយល់ឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ ពាក់ព័ន្ធទៅនឹងអំពើ**មនុស្សឃាតលើជនជាតិវៀតណាម និងអំពើប្រល័យពូជសាសន៍**។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញដែលថា អំពើមនុស្សឃាតលើជនជាតិវៀតណាមត្រូវបានប្រព្រឹត្តឡើងនៅតាមសហករណ៍នានា និងលើទឹកដីកម្ពុជា និងជំទាស់បន្ថែមទៀតថា បទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយចេតនាតម្រូវតាមលក្ខខណ្ឌក្នុងការកម្ទេចក្រុមជនជាតិភាគតិចវៀតណាម។

៣៨. ជាចុងក្រោយ ជនជាប់ចោទបានអះអាងថា អ្នកជាប់ឃុំជនជាតិវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ និងមន្ទីរសន្តិសុខអូរកន្សែង ឬនៅឯសមុទ្រ ពុំមែនជាសមាជិកនៃក្រុមដែលត្រូវបានការពារដែលផ្អែកលើមូលដ្ឋានតែមួយគត់ដែលថា អ្នកទាំងនោះជាជនជាតិវៀតណាមនោះទេ។

៣៩. ខ្ញុំសូមបញ្ចប់របាយការណ៍ស្តីពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធ។

## IV. **របាយការណ៍របស់សហចៅក្រមរបាយការណ៍សម្រាប់វគ្គស្ដីពី“ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទ”** *សហចៅក្រមរបាយការណ៍៖* **ចៅក្រម សោម សិរីវឌ្ឍ និងចៅក្រម Maureen Harding CLARK**

៤០. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានរៀបរាប់ពីខាងដើមក្រោមទម្រង់នៃការទទួលខុសត្រូវពីរ៖ សហឧក្រិដ្ឋកម្មរួម និងការជួយទំនុកបម្រុងដល់បទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលពុំស្ថិតក្នុងសហឧក្រិដ្ឋកម្មរួម។

៤១. ដំបូង ជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវជាលក្ខណៈបុគ្គលតាមរយៈការចូលរួមរបស់គាត់ក្នុងគោលបំណងរួម និងរួមចំណែកក្នុងចេតនាឧក្រិដ្ឋដូចគ្នានៃសហឧក្រិដ្ឋកម្មរួម។ ការសម្រេចដាក់ពិរុទ្ធទាំងនោះគឺសម្រាប់បទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃការអនុវត្តន៍គោលនយោបាយប្រាំចំណុចរបស់បក្សកុម្មុយនីស្តកម្ពុជាពេញមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយទាំងនោះមាន៖ ១) ការផ្លាស់ទីប្រជាជនពីទីក្រុងទៅតាមជនបទនានា ២) ការបង្កើត និងការប្រតិបត្តិសហករណ៍ និងការដ្ឋានធ្វើការ ៣) ការបង្កើត និងការប្រតិបត្តិមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ៤) ការកំណត់គោលដៅក្រុមជាក់លាក់ ដូចជា ជនជាតិចាម វៀតណាម អ្នកកាន់ពុទ្ធសាសនា អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ និង ៥) បទបញ្ញារៀបអាពាហ៍ពិពាហ៍។ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ជនជាប់ចោទសម្រាប់បទឧក្រិដ្ឋដោយសារជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម បានផ្អែកលើមូលដ្ឋានថាគាត់បានរួមចំណែកក្នុងចេតនារើសអើង ជាក់លាក់ និងផ្ទាល់ជាមួយសមាជិកនៃសហឧក្រិដ្ឋកម្មរួមដទៃទៀត។

៤២. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ត្រឹមថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តរហូតមកដល់យ៉ាងហោចណាស់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ជនជាប់ចោទ ដែលជាមេដឹកនាំជាន់ខ្ពស់ក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា បានចូលរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមនូវគោលបំណងរួមដើម្បីអនុវត្តបដិវត្តន៍សង្គមនិយមឆាប់រហ័សក្នុងកម្ពុជាតាមរយៈផែនការ‘មហាលោតផ្លោះមហាអស្ចារ្យ’ ដែលបានបង្កើតឡើងដើម្បីកសាងប្រទេស ការពារពីសត្រូវ និងប្រែក្លាយប្រជាជនទាំងស្រុងឱ្យទៅជាសង្គមកម្មករកសិករខ្មែរមួយដែលគ្មានការបែកចែកវណ្ណៈ និងសាសនា។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា គោលបំណងរួមនេះ ពុំមែនជាបទឧក្រិដ្ឋចាំបាច់ដោយខ្លួនឯងផ្ទាល់នោះទេ ប៉ុន្តែ តាមការអនុវត្តន៍ជោគជ័យនៃគោលបំណងជាចុងក្រោយបានកំណត់ចរិតលក្ខណៈឧក្រិដ្ឋនៃគោលបំណងរួមនេះដោយសារគោលបំណងនេះ៖

*“អាចកើតឡើងបានអាស្រ័យលើការអនុវត្តគោលនយោបាយអាក្រក់ និងការលុបបំបាត់សមាសធាតុទាំងអស់ដែលប្រឆាំងបដិវត្តន៍”។*

៤៣. អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា តួនាទីរបស់ជនជាប់ចោទក្នុងគោលបំណងរួម មានអត្ថិភាពតាមរយៈការរួមចំណែករបស់គាត់យ៉ាងសំខាន់នៅក្នុងការគាំទ្រជាសាធារណៈ ការជម្រុញ និងការយល់ស្របតាមគោលដៅតាមរយៈតួនាទីជាន់ខ្ពស់របស់គាត់នៅក្នុងបក្សកម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ និងតាមរយៈការដឹកនាំផ្ទាល់ខ្លួននៃវគ្គរៀនសូត្រ និងការជួបជុំដោយបានណែនាំ បញ្ចុះបញ្ចូល និងផ្តល់ការគាំទ្រដល់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។

៤៤. ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ក្នុងតួនាទីជាន់ខ្ពស់របស់គាត់នៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ជនជាប់ចោទបានជួយទំនុកបម្រុងបទឧក្រិដ្ឋនៃអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ*ដោយចេតនាប្រយោល*នៅតាមទីកន្លែងប្រព្រឹត្តបទឧក្រិដ្ឋនានា។

៤៥. ជនជាប់ចោទជានិច្ចកាលតែងតែបដិសេធថា គាត់មានតួនាទី និងមុខតំណែងជាន់ខ្ពស់ក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬថា គាត់បានដឹងនូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលស្ថិតក្រៅដែនកំណត់នៃការទទួលខុសត្រូវរបស់គាត់ដែលមានត្រឹមតែការបញ្ជាទិញ និងការចែកចាយរបស់របរចាំបាច់ដូចជា ថ្នាំពេទ្យជាដើម និងការទំនាក់ទំនងរវាងសម្តេចព្រះនរោត្តមសីហនុ និងបក្សកុម្មុយនីស្តកម្ពុជា និងជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលមានតែឈ្មោះ។

៤៦. គាត់បានលើកទឡ្ហីករណ៍ផ្សេងៗនៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់គាត់ក្រោមទម្រង់នៃការទទួលខុសត្រូវទាំងពីរប្រភេទ។ ទាក់ទងនឹងការទទួលខុសត្រូវក្រោមទម្រង់**សហឧក្រិដ្ឋកម្មរួម** ជនជាប់ចោទបានលើកអំណះអំណាងជាច្រើនប្រឆាំងនឹងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងចំពោះភស្តុតាង និងការយល់ឃើញ ដែលអំណះអំណាងនេះអាចត្រូវបានដាក់តាមប្រភេទ និងសង្ខេបដូចខាងក្រោម៖

៤៧. អំណះអំណាងទីមួយ គឺពាក់ព័ន្ធទៅនឹងមូលដ្ឋានផ្លូវច្បាប់នៃទស្សនៈស្តីពីការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម។ ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសជាច្រើនផ្សេងៗគ្នា។ កំហុសទីមួយកើតឡើងនៅពេលអង្គជំនុំជម្រះបានយកបទដ្ឋានផ្លូវច្បាប់ពុំត្រឹមត្រូវមកអនុវត្តក្នុងការវាយតម្លៃទំនាក់ទំនងរវាងចារីផ្ទាល់ និងអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។ គាត់បានលើកឡើងថា នៅពេលដែលអ្នកចូលរួមម្នាក់ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះអំពើដែលបានត្រូវបានប្រព្រឹត្តដោយចារីដទៃទៀត គឺតម្រូវឱ្យមាន

**ការកំណត់និយមន័យមួយដែលមានលក្ខណៈចង្អៀតអំពីគោលបំណងរួមនេះ។** ជនជាប់ចោទពុំបានជំទាស់ថា គោលបំណងនៃសហឧក្រិដ្ឋកម្មរួមអាចវិវឌ្ឍតាមពេលវេលា ដូច្នេះអាចមានការបញ្ចូលបទឧក្រិដ្ឋបន្ថែមនៅក្នុងគោលបំណងរួមនោះ ប៉ុន្តែគាត់អះអាងថា ការវិវឌ្ឍន៍ និងចំណុចដែលថា សមាជិកនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីការប្រព្រឹត្តបទឧក្រិដ្ឋដែលបានបន្ថែមនោះ ពុំត្រូវបានពិពណ៌នាឱ្យបានច្បាស់លាស់ដោយអង្គជំនុំជម្រះសាលាដំបូងឡើយ។ ទីពីរ ជនជាប់ចោទជំទាស់ទៅនឹងទស្សនៈដែលថា **បទឧក្រិដ្ឋ**ដែលបានប្រព្រឹត្តក្រោមទម្រង់នៃ**សហឧក្រិដ្ឋកម្មរួម** អាចជាអំពើ**អសកម្ម**។ ទីបី គាត់អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបានបន្ទាបបទដ្ឋាននៃចេតនាផ្ទាល់តម្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។

៤៨. អំណះអំណាងទីពីរ គឺពាក់ព័ន្ធទៅនឹង**គោលបំណងរួម**។ ជនជាប់ចោទលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសបីសំខាន់ៗ។ ដោយសារគោលបំណងរួមដែលបានកំណត់អត្តសញ្ញាណដោយអង្គជំនុំជម្រះសាលាដំបូង ដែលជាការអនុវត្តនៃបដិវត្តន៍សង្គមនិយមឆាប់រហ័សនោះ ពុំមែនជាបទឧក្រិដ្ឋខ្លួនឯងផ្ទាល់ ទើបអង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅពេលយល់ឃើញថា គោលបំណងរួមក្លាយជាបទល្មើសដោយសារមានការប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាជាងតាមរយៈការពិនិត្យលើផែនការនយោបាយដែលពុំមែនជាបទល្មើសរបស់បក្សកុម្មុយនីស្តកម្ពុជា។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្ទាបលក្ខខណ្ឌតម្រូវសម្រាប់ការទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម ដោយសារអង្គជំនុំជម្រះបានកំណត់យកលក្ខណៈឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មរួមផ្អែកលើគោលនយោបាយជាជាងលើគោលបំណងរួម។

៤៩. អំណះអំណាងទីបី គឺពាក់ព័ន្ធទៅនឹងការយល់ឃើញអំពី**ការរួមចំណែក**របស់ជនជាប់ចោទទៅក្នុងការអនុវត្តន៍**គោលបំណងរួម**។ ដំបូង ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុដោយសារ**ពុំមានភស្តុតាងគ្រប់គ្រាន់**អាចឱ្យយល់ឃើញថា គាត់បានរួមចំណែកយ៉ាងសំខាន់ក្នុងបទឧក្រិដ្ឋ ឬថាអង្គជំនុំជម្រះខកខានក្នុងការបង្ហាញភស្តុតាងអំពីការរួមចំណែកយ៉ាងសំខាន់ ដែលជាធាតុផ្សំចាំបាច់សម្រាប់ការទទួលខុសត្រូវក្រោមទម្រង់នៃសហឧក្រិដ្ឋកម្មរួម។ ពិសេសជាងនេះទៅទៀត គាត់បានអះអាងថា ការពាក់ព័ន្ធរបស់គាត់ជាមួយនឹងសមាជិកនៃគណៈអចិន្ត្រៃយ៍ ពុំមានលក្ខណៈគ្រប់គ្រាន់ក្នុងការបង្ហាញនូវការរួមចំណែកយ៉ាងសំខាន់នៅក្នុងទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយឡើយ។ ទីពីរ គាត់បានជំទាស់លើភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការយល់ឃើញអំពីអង្គហេតុជាក់លាក់ស្តីពីតួនាទីរបស់គាត់ និងសិទ្ធិអំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យ។ ទីបី គាត់បានលើកឡើងថា ការវាយតម្លៃលើភស្តុតាងដើម្បីបង្ហាញពី

ការរួមចំណែករបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម មានលក្ខណៈលម្អៀង និងមិនបានគ្រប់ជ្រុងជ្រោយ។ **<u>អង្គជំនុំជម្រះតុលាការកំពូលស្វាគមន៍ការបង្ហាញជាក់លាក់លើបញ្ហានេះ</u>**។

៥០. អំណះអំណាងចុងក្រោយ គឺពាក់ព័ន្ធទៅនឹងការដឹងរបស់ជនជាប់ចោទអំពីបទឧក្រិដ្ឋ។ គួររំឭកថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយ តម្រូវឱ្យមានចេតនាផ្ទាល់ និងការដឹងអំពីបទឧក្រិដ្ឋ តាមការអះអាង គាត់បានលើកជាញឹកញាប់ថា គាត់**ពុំបានដឹងអំពីបទឧក្រិដ្ឋ** និងជាពិសេស អំពីលក្ខខណ្ឌរស់នៅ និងធ្វើការដែលបានដាក់នៅសហករណ៍ និងការដ្ឋានការងារឡើយ។ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងជាទូទៅពុំបានទទួលស្គាល់អំពីគោលការណ៍តឹងរ៉ឹងនៃការសម្ងាត់ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងថា ការយល់ឃើញពាក់ព័ន្ធទៅនឹងការដឹងរបស់គាត់អំពីប្រព័ន្ធទំនាក់ទំនងនៃបក្សកុម្មុយនីស្តកម្ពុជា មានកំហុស។ គាត់បានអះអាងថា គាត់ពុំបានដឹងពិតប្រាកដអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទូទាំងប្រទេស។

៥១. ចំពោះការទទួលខុសត្រូវរបស់គាត់ដោយសារ**ការជួយទំនុកបម្រុង** គាត់អះអាងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គហេតុ និងអង្គច្បាប់។ គាត់លើកអំណះអំណាងពីរសំខាន់ៗ៖ ទីមួយ អង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យពុំត្រឹមត្រូវអំពីធាតុផ្សំ*អត្តនោម័ត*នៃការជួយទំនុកបម្រុង។ នៅពេលដែលអង្គជំនុំជម្រះបានអនុម័តតាមបទដ្ឋានដែលថា ដើម្បីឱ្យជនជាប់ចោទជាប់ពិរុទ្ធចំពោះការទទួលខុសត្រូវដែលជាការសមគំនិត គាត់ត្រូវតែដឹងថា បទឧក្រិដ្ឋទំនងជាត្រូវបានប្រព្រឹត្តឡើង អង្គជំនុំជម្រះសាលាដំបូងបន្ទាប់មកបានអនុវត្តដោយពុំសមហេតុផលនូវចេតនាក្នុងកម្រិតមួយទាបជាង ដែលពុំត្រូវបានគ្របដណ្តប់ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលច្បាប់នេះមានអត្ថិភាពក្នុងពេលដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើង។ គាត់ជំទាស់ជាពិសេសទៅនឹងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ **ICTY** ចេញពីសេចក្តីសម្រេចស្តីពីការជួយទំនុកបម្រុងនៅក្នុង*រឿងក្តី* ***Furundzija, Akayesu និង Blaskic*** ។

៥២. គាត់ជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ធាតុផ្សំអត្តនោម័តនៃការជួយទំនុកបម្រុង ត្រូវបានបង្ហាញ។ ការយល់ឃើញដែលថា៖ *"នៅពេលនោះ គាត់បានដឹងអំពីធាតុផ្សំចាំបាច់នៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយចារីផ្ទាល់"* ត្រូវបដិសេធចោល ដោយគាត់លើកឡើងថា មានភស្តុតាងគាំទ្រការជំទាស់របស់គាត់ដែលថា គាត់ពុំបានដឹងអំពីភវនីយភាពដែលថា ការស្លាប់បានបណ្តាលមកពីលក្ខខណ្ឌដែលបានដាក់ចេញនៅការដ្ឋានធ្វើការ និងសហករណ៍ និងពុំបានដឹងថា អំពើមនុស្សឃាតត្រូវបានប្រព្រឹត្តឡើង

នៅមន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស។ **<u>ជនជាប់ចោទអាចប្រាប់អង្គជំនុំជម្រះអំពីភស្តុតាងដែលគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា ជនជាប់ចោទពុំបានដឹងអំពីការស្លាប់ និងការសម្លាប់នៅការកន្លែងទាំងនោះ។</u>**

៥៣. ទីពីរ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការយល់ឃើញថា ធាតុផ្សំ *សត្យានុម័ត*នៃការជួយទំនុកបម្រុងក្នុងអំពើមនុស្សឃាត *ដោយចេតនាប្រយោល* បំពេញតាមលក្ខខណ្ឌតម្រូវ នៅតាមការដ្ឋានធ្វើការ និងមន្ទីរសន្តិសុខនានា។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការគាំទ្រផ្នែកសីលធម៌ ការលើកទឹកចិត្តដោយប្រយោល ឬការជួយជាក់ស្តែងដល់ស្ថាប័នធ្វើសេចក្តីសម្រេចនៃបក្សកុម្មុយនីស្តកម្ពុជា និងទស្សនកិច្ចតាមកន្លែងមួយចំនួននេះជះឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រព្រឹត្តអំពើមនុស្សឃាតទាំងនោះ។ ចុងក្រោយ ជនជាប់ចោទអះអាងថា ត្រឹមតែវត្តមានរបស់គាត់នៅពេលប្រជុំពុំអាចស្មើទៅនឹងការជួយទំនុកបម្រុងឡើយ។ ជាថ្មីម្តងទៀត គាត់បានជំទាស់ទៅនឹងភាពត្រឹមត្រូវតាមច្បាប់នៃការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសេចក្តីសម្រេចស្តីពីការជួយទំនុកបម្រុងនៅក្នុងរឿងក្តី ***Furundzija, Akayesu*** *និង* ***Blaskic*** ។

៥៤. ខ្ញុំសូមបញ្ចប់របាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល។

## V. របាយការណ៍របស់សហចៅក្រមរបាយការណ៍សម្រាប់ទគ្គស្តី"ទស្សីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការប្រកាសទោស"

*សហចៅក្រមរបាយការណ៍៖* **ចៅក្រម JUDGE CHANDRA NIHAL JAYASINGHE និងចៅក្រម ម៉ុង មុន្នីចរិយា**

៥៥. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចប្រកាសទោសជនជាប់ចោទជាប់ពន្ធនាគារអស់មួយជីវិតពីបទឧក្រិដ្ឋដែលគាត់ត្រូវបានសម្រេចដាក់ពិរុទ្ធ។ ការប្រកាសទោសនេះត្រូវធ្វើឡើងស្របគ្នាជាមួយនឹងការប្រកាសទោសអស់មួយជីវិតលើកមុនដែលបានដាក់ពីបទឧក្រិដ្ឋដែលមាននៅក្នុងសំណុំរឿង ០០២/០១ និងត្រូវបានប្រកាសតម្កល់ដោយអង្គជំនុំជម្រះតុលាការកំពូល។ នៅក្នុងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ខ្លួន ជនជាប់ចោទលើកអំណះអំណាងបួនចំណុចសំខាន់ៗជំទាស់ទៅនឹងភាពត្រឹមត្រូវនៃការប្រកាសទោសនោះ ដែលត្រូវបានសង្ខេបដូចខាងក្រោម៖

៥៦. ទីមួយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបញ្ជាក់ថា គោលដៅបឋមនៃការប្រកាសទោសគឺដើម្បីធានាដល់ជនរងគ្រោះ សាក្សី និងសាធារណជនថា ច្បាប់កំពុងត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងអនុវត្តលើគ្រប់រូបទាំងអស់ ដោយមិនគិតពីឋានៈឡើយ។ ជនជាប់ចោទបានអះអាងថា នេះគឺជាគោលដៅទីពីរនៃការដាក់ទោស និងបង្ហាញពីភាពលម្អៀង។ ការប្រកាសទោសនោះមានលក្ខណៈធ្ងន់ធ្ងរហួសហេតុ។

៥៧. ទីពីរ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់នៅក្នុងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដោយសារអង្គជំនុំជម្រះបានពិចារណាលើបទឧក្រិដ្ឋដែលជនជាប់ចោទពុំត្រូវបានចោទប្រកាន់ ឬដាក់ពិរុទ្ធ។ ជាឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើការរំលោភសេពសន្ថវៈអ្នកជាប់ឃុំក្នុងមន្ទីរសន្តិសុខ។ ដោយសារតែបញ្ហាដែលបានបង្ហាញហួសពីវិមតិសង្ស័យនេះ ត្រូវបានពិចារណាប្រឆាំងនឹងជនជាប់ចោទនៅដំណាក់កាលដាក់ទោស ទើបធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើគោលការណ៍នៃការដាក់ទោស។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើលក្ខណៈ និងវិសាលភាពមានកម្រិត និងដោយប្រយោលនៃការចូលរួមរបស់គាត់ក្នុងឧក្រិដ្ឋកម្ម នៅពេលធ្វើការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ដូច្នេះ បានរំលោភបំពានលើការអនុវត្តន៍ស្តីពីការដាក់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលការចូលរួមប្រយោល ឬមិនសំខាន់ តាមធម្មតា នាំទៅរកការប្រកាសទោសក្នុងកម្រិតស្រាលជាង។

៥៨. ទីបី ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ និងអង្គហេតុក្នុងការវាយតម្លៃរបស់ខ្លួនលើ**ស្ថានទម្ងន់ទោស**ពីរចំណុច (i) អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកការរំលោភតួនាទីនៃសិទ្ធិអំណាចរបស់គាត់ និងឥទ្ធិពល ជាស្ថានទម្ងន់ទោសមួយ ដែលផ្ទុយគ្នាទៅនឹងការយល់ឃើញរបស់ខ្លួនដែលថា ជនជាប់ចោទពុំមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការបញ្ជាដោយផ្ទាល់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ។ តួនាទីនៃសិទ្ធិអំណាចរបស់គាត់ត្រូវបានយកមកពិចារណារួចរាល់ហើយក្នុងអំឡុងពេលនៃការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ។ (ii) អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយបង្ហាញពីភាពពាក់ព័ន្ធ និងទំនាក់ទំនងនៃកម្រិតចំណេះដឹងរបស់គាត់ ថាជាស្ថានទម្ងន់ទោស។

៥៩. ទីបួន ជនជាប់ចោទអះអាងថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការវាយតម្លៃអំពី**ស្ថានសម្រាលទោស**។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ការពិចារណាសមស្របលើ**ការសហការ**របស់គាត់ជាមួយនឹង អ.វ.ត.ក. រួមទាំងការចូលរួមយ៉ាងសកម្មរបស់គាត់នៅពេលជំនុំជម្រះ អត្តចរិតល្អប្រសើររបស់គាត់ក្នុងអំឡុងពេលឃុំខ្លួន និងការទទួលស្គាល់នូវការរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់ទម្ងន់គ្រប់គ្រាន់ដល់**បញ្ហាវ័យចាស់របស់គាត់ និងស្ថានភាពសុខភាព** និងលទ្ធភាពពុំអាចទ្រាំទ្រការដាក់ក្នុងមន្ទីរឃុំឃាំងរយៈពេលយូរ។ ទីបី អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយពុំបានធ្វើការវាយតម្លៃថ្មីមួយអំពីតម្លៃដែលត្រូវផ្តល់ចំពោះសាក្សីចរិតលក្ខណៈ និងដោយខកខានក្នុងការពិចារណារាល់សមាសធាតុទាំងអស់នៃបុគ្គលិកលក្ខណៈរបស់គាត់ និងមិនអើពើលើចំណុចល្អៗគួរឱ្យសរសើរព្រមគ្នារបស់។

៦០. សរុបសេចក្តីមក ជនជាប់ចោទបានលើកឡើងថា កំហុសទាំងនេះធ្វើឱ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូទៅជាមោឃៈស្តីពីការប្រកាសទោសលើរូបគាត់ ដែលតាមការអះអាងរបស់គាត់ គប្បីត្រូវកាត់បន្ថយត្រឹមជាប់ពន្ធនាគារមានរយៈពេលកំណត់។

៦១. ខ្ញុំសូមបញ្ចប់របាយការណ៍ស្តីពីទឡ្ហីករណ៍បណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងការប្រកាសទោស។

## VI. សហចៅក្រមរបាយការណ៍សម្រាប់វគ្គស្តីពី"បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា"

*សហចៅក្រមរបាយការណ៍៖* **ចៅក្រម FLORENCE NDEPELE MWACHANDE MUMBA និងចៅក្រម យ៉ា ណារិន**

៦២. សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខតែមួយ និងបានជំទាស់ទៅនឹងវិធីសាស្ត្រដែលអង្គជំនុំជម្រះសាលាដំបូងដោះស្រាយលើអានុភាពនៃការបង្ខំរួមសង្វាស ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំលើបុរស និងថា អាពាហ៍ពិពាហ៍នោះត្រូវបានរៀបចំឡើងជាមួយស្ត្រីដែលពួកគាត់ពុំបានស្គាល់ និងបានដឹង ឬយល់ព្រមជាមួយ។ អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ផ្អែកលើអង្គហេតុទាំងនោះ បុរសពុំអាចក្លាយជារងគ្រោះនៃការរំលោភសេពសន្ថវៈឡើយ។ សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងការយល់ឃើញនេះ ប៉ុន្តែជំទាស់ទៅលើការធ្វើឱ្យត្រឹមត្រូវស្របច្បាប់នៃការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវាយតម្លៃលើបញ្ហា ថាតើបុរសក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទក្នុងកម្រិតធ្ងន់ធ្ងរដែលអាចស្មើនឹងអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា។ បើទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា បុរសត្រូវបានដាក់ឱ្យស្ថិតក្រោមអំពើហិង្សាផ្លូវភេទដែលផ្ទុយទៅនឹងសេចក្តីថ្លៃថ្នូរបស់មនុស្សក៏ដោយ ក៏នៅតែយល់ឃើញថា ដោយសារពុំមានភស្តុតាងច្បាស់លាស់បង្ហាញថាអំពើប្រភេទនេះមានកម្រិតធ្ងន់ធ្ងរលើបុរស ទើបអង្គជំនុំជម្រះពុំអាចធ្វើការយល់ឃើញបានស្តីពីភាពធ្ងន់ធ្ងរនៃការរងទុក្ខផ្លូវកាយ និងផ្លូវចិត្តដែលកើតមានលើបុរសទាំងនោះ។ សហព្រះរាជអាជ្ញាលើកឡើងថា ជនរងគ្រោះទាំងបុរស និងស្ត្រីនៃអំពើបង្ខំរួមភេទដូចគ្នា គប្បីត្រូវបានទទួលស្គាល់យ៉ាងត្រឹមត្រូវថា ជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ ដែលជាប្រភេទមួយផ្សេងទៀតនៃអំពើអមនុស្សធម៌នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

៦៣. សហព្រះរាជអាជ្ញាបានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងការដកជនរងគ្រោះជាបុរសនៃអំពើហិង្សាផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ចេញពីការដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈអំណះអំណាងពីរជាបឋម។

៦៤. ទីមួយ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ដោយសារខកខានក្នុងការអនុវត្តនូវលក្ខខណ្ឌតម្រូវផ្នែកច្បាប់លើឧក្រិដ្ឋកម្មឱ្យបានត្រឹមត្រូវដោយពុំបានពិចារណាលើបញ្ហាថាតើការបង្ខំនរណាម្នាក់ឱ្យរួមភេទ គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរបស់មនុស្ស ដែរ ឬយ៉ាង។ ទី

ពីរ សហព្រះរាជអាជ្ញាបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ ដោយសារពុំបានយល់ឃើញថា ការបង្ខំបុរសឱ្យរួមភេទ បានបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរទាំងផ្លូវកាយ និងផ្លូវចិត្តចំពោះជនរងគ្រោះជាបុរស។ សហព្រះរាជអាជ្ញាបានជំទាស់នៅនឹងការធ្វើឱ្យទៅជាត្រឹមត្រូវស្របច្បាប់នៃការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិចារណាឱ្យបានត្រឹមត្រូវលើភស្តុតាងពាក់ព័ន្ធ ឬផ្តល់សំអាងហេតុពេញលេញលើការយល់ឃើញរបស់ខ្លួនដែលថា អំពើអមនុស្សធម៌ដទៃទៀតពុំមានអត្ថិភាពនោះ។ សហព្រះរាជអាជ្ញាបានលើកឡើងថា កំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ មានភាពធ្ងន់ធ្ងរដែលនាំឱ្យសេចក្តីសម្រេចនោះទៅជាមោឃៈដោយសារមានភាពមិនយុត្តិធម៌។

៦៥. សហព្រះរាជអាជ្ញាបានលើកឡើង អំពើសកម្ម ឬអសកម្មនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ដទៃទៀតមានអត្ថិភាព ដរាបណាអំពើនោះបានបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត *ឬក៏* ជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ពាក់ព័ន្ធបញ្ហានេះ សហព្រះរាជអាជ្ញាបានអះអាងថា កិច្ចការក្នុងការកំណត់លើបញ្ហា ថាតើអំពើនោះ គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សមកលើជនរងគ្រោះ ដែរ ឬយ៉ាងណា គឺជាកត្តាសត្យានុម័ត ហើយប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមវិធីសាស្ត្រត្រឹមត្រូវ ប្រាកដជាបានយល់ឃើញថា អំពើនោះ គឺស្មើនឹងការវាយប្រហារយ៉ាងធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សមកលើជនរងគ្រោះជាបុរស។

៦៦. សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភស្តុតាងដែលជាប់ពាក់ព័ន្ធជាសត្យានុម័ត នៅក្នុងការបង្ហាញពីការរងទុក្ខរបស់ជនរងគ្រោះជាបុរសដែលបានបង្កឡើងដោយសារ ភាពជាជនរងគ្រោះខ្លួនឯងផ្ទាល់នៃការបង្ខំឱ្យរួមសង្វាសផង និងត្រូវបានតម្រូវឱ្យបង្កការឈឺចាប់លើប្រពន្ធរបស់ខ្លួនក្នុងកាលៈទេសៈបង្ខិតបង្ខំនោះ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងពុំអើពើសក្ខីកម្មរបស់អ្នកជំនាញពាក់ព័ន្ធ និងភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីនៃការរងទុក្ខរបស់បុរសដែលបានបង្កឡើងដោយសារការបង្ខំឱ្យរួមដំណេក។ សហព្រះរាជអាជ្ញាបានលើកឡើងថា ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងរួមទាំងនៅពេលដែលបុរសពុំអាចបដិសេធរួមដំណេកការរៀបអាពាហ៍ពិពាហ៍បាន មានលក្ខណៈគ្រប់គ្រាន់ខ្លួនឯងក្នុងការបង្ហាញពីកម្រិតនៃអំពើធ្ងន់ធ្ងរ និងផលប៉ះពាល់លើបុរស។

**៦៧. អង្គជំនុំជម្រះតុលាការកំពូលអញ្ជើញសហព្រះរាជអាជ្ញាបង្ហាញ ថាតើ មានភស្តុតាងរបស់សាក្សីដែលពុំមែនជាភស្តុតាងតាមការសន្និដ្ឋាន អ្វីខ្លះ ពុំត្រូវបានពិចារណា នៅពេលអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថាពុំមានភស្តុតាងច្បាស់លាស់បង្ហាញអំពើប្រភេទនេះមានកម្រិតធ្ងន់ធ្ងរ និងផលប៉ះពាល់លើបុរស។**

៦៨. ខ្ញុំសូមបញ្ចប់របាយការណ៍ស្ដីពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។